ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ
លេខ:..................អសជ/.....

# របាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន នៅខេត្តឧត្តរមានជ័យ

## ការិយបរិច្ឆេទ ២០២៣

អគារលេខ ៥ ផ្លូវឌួងងៀប៣ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ
# 5, St. Duong Ngeab 3, Sangkat Tekthla, Khan Sensok, Phnom Penh, CAMBODIA
Tel:(855-23) 885 900, (855-12) 737 622 Fax: (855-23) 885 900
E-mail: naakh@naa.gov.kh website: www.naa.gov.kh

**របាយការណ៍សង្ខេប**

អនុលោមតាមមាត្រា២ មាត្រា៣ និងមាត្រា៩ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ អាជ្ញាធរសវនកម្មជាតិ មានភារកិច្ចធ្វើសវនកម្មលើបណ្តាក្រសួង ស្ថាប័ន រាជធានី ខេត្ត។ អាជ្ញាធរសវនកម្មជាតិបានកំណត់ជ្រើសរើសយកការធ្វើសវនកម្មលើកិច្ចប្រតិបត្តិការស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាននៅខេត្តឧត្តរមានជ័យ សម្រាប់ការិយបរិច្ឆេទ២០២៣ ក្នុងគោលបំណងដើម្បីធានាបាននូវភាពសន្សំសំចៃ ប្រសិទ្ធភាព និងប្រសិទ្ធផល ក្នុងការអនុវត្តការងារដោយផ្សាភ្ជាប់ទៅនឹងគោលបំណងសំខាន់ៗនៃអភិបាលកិច្ចល្អ និងគណនេយ្យភាពក្នុងការគ្រប់គ្រងវិស័យកសិកម្មរបស់រាជរដ្ឋាភិបាល ។

ការធ្វើសវនកម្មលើកិច្ចប្រតិបត្តិការនេះ គឺដើម្បីវាយតម្លៃថាតើ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តឧត្តរមានជ័យ ធ្វើការគ្រប់គ្រងសត្តឃាតដ្ឋាននៅខេត្តឧត្តរមានជ័យ ប្រកបដោយភាពសន្សំសំចៃ ប្រសិទ្ធភាព និងប្រសិទ្ធផលដែរឬទេ?

តាមរយៈការធ្វើសវនកម្មលើកិច្ចប្រតិបត្តិការស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាននៅខេត្តឧត្តរមានជ័យ សម្រាប់ការិយបរិច្ឆេទ២០២៣ និងឆ្នាំពាក់ព័ន្ធ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានអនុវត្តការងាររបស់ខ្លួនបានល្អប្រសើរលើការគ្រប់គ្រងសត្តឃាតដ្ឋានស្របតាមចក្ខុវិស័យនៃគោលនយោបាយជាតិអភិវឌ្ឍវិស័យកសិកម្មរបស់រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ២០២២-២០៣០ និងមានការពេញចិត្តច្រើនពីសំណាក់ប្រជាពលរដ្ឋ ព្រមទាំងមានការទទួលខុសត្រូវ និងប្តេជ្ញាចិត្តខ្ពស់ពីសំណាក់ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ (ខេត្ត ក្រុង និងស្រុក)។

ទន្ទឹមនឹងការអនុវត្តដ៏ល្អនេះ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏នៅមានចំណុចខ្វះខាតមួយចំនួនដែលគួរធ្វើការកែលម្អបន្ថែមទៀត ដើម្បីឱ្យការគ្រប់គ្រងសត្តឃាតដ្ឋាននៅខេត្តឧត្តរមានជ័យកាន់តែមានភាពប្រសើរឡើង ដូចខាងក្រោម៖

**១. ការរៀបចំកន្លែងបង្ខាំងសត្វមុនពិឃាតពុំទាន់ត្រឹមត្រូវ**

តាមគោលការណ៍នៃការគ្រប់គ្រងសត្តឃាតដ្ឋាន និងបទដ្ឋានបច្ចេកទេសសម្រាប់ការសាងសង់សត្តឃាតដ្ឋាន បានតម្រូវឱ្យម្ចាស់សត្តឃាតដ្ឋានដែលបានបង្កើតសត្តឃាតដ្ឋានធ្វើការរៀបចំកន្លែងសម្រាប់ដាក់សត្វដែលមានជំងឺ ឬសង្ស័យថាមានជំងឺ ដើម្បីពិនិត្យសុខភាពសត្វមុនពេលពិឃាត ព្រមទាំងធានាបាននូវការអនុវត្តវិធានបសុព្យាបាល អនាម័យ សុវត្ថិភាពសាច់ និងផលិតផលសត្វ ជាប្រយោជន៍ការពារសុខភាពសាធារណៈ និងបរិស្ថាន។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការរៀបចំកន្លែងបង្ខាំងសត្វមុនពិឃាតពុំទាន់ត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសនៅឡើយ ដោយម្ចាស់សត្តឃាតដ្ឋានពុំបានរៀបចំកន្លែងបង្ខាំងសត្វដែលមានជំងឺ ឬសង្ស័យមានជំងឺឱ្យដាច់ដោយឡែកពីគ្នា។ បញ្ហានេះ កើតមានឡើងដោយសារម្ចាស់សត្តឃាតដ្ឋានពុំបានរៀបចំកន្លែងបង្ខាំងសម្រាប់ដាក់សត្វដែលមានជំងឺ ឬសង្ស័យថាមានជំងឺ និងកង្វះខាតការយល់ដឹងរបស់ម្ចាស់សត្តឃាតដ្ឋានក្នុងការអនុវត្តភារកិច្ចរបស់ខ្លួនឱ្យសមស្របតាមគោលការណ៍នៃការគ្រប់គ្រងសត្តឃាតដ្ឋាន និងបទដ្ឋានបច្ចេកទេស។

២. កង្វះខាតក្នុងការទុកដាក់សំណល់សត្វ

តាមគោលការណ៍នៃការគ្រប់គ្រងសត្តឃាតដ្ឋាន និងបទដ្ឋានបច្ចេកទេសសម្រាប់ការសាងសង់សត្តឃាតដ្ឋាន បានតម្រូវឱ្យម្ចាស់សត្តឃាតដ្ឋានដែលបានបង្កើតសត្តឃាតដ្ឋានធ្វើការរៀបចំកន្លែងសម្រាប់ដាក់សំណល់សត្វ មិនអាចបរិភោគបានជាអាទិ៍ ឆ្អឹង រោម ស្បែក ស្នែង ក្រចក និងលាមក ព្រមទាំងធានាបាននូវការអនុវត្តវិធានបសុព្យាបាល អនាម័យ សុវត្ថិភាពសាច់ និងផលិតផលសត្វ ជាប្រយោជន៍ការពារសុខភាពសាធារណៈ និងបរិស្ថាន។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការទុកដាក់សំណល់សត្វពុំទាន់ត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសនៅឡើយ ដោយម្ចាស់សត្តឃាតដ្ឋានពុំបានរៀបចំកន្លែងសម្រាប់ដាក់សំណល់សត្វនោះទេ។ បញ្ហានេះ កើតមានឡើងដោយសារម្ចាស់សត្តឃាតដ្ឋានពុំបានរៀបចំកន្លែងសម្រាប់ដាក់សំណល់សត្វមិនអាចបរិភោគបានជាអាទិ៍ ឆ្អឹង រោម ស្បែក ក្រចក និងលាមក និងកង្វះខាតការយល់ដឹងរបស់ម្ចាស់សត្តឃាតដ្ឋានក្នុងការអនុវត្តភារកិច្ចរបស់ខ្លួនឱ្យសមស្របតាមគោលការណ៍នៃការគ្រប់គ្រងសត្តឃាតដ្ឋាន និងបទដ្ឋានបច្ចេកទេស។

**៣. ការពុំបានរៀបចំប្រព័ន្ធបង្ហូរកាកសំណល់ឱ្យស្របតាមលក្ខណៈបច្ចេកទេស**

តាមគោលការណ៍នៃការគ្រប់គ្រងសត្តឃាតដ្ឋាន និងបទដ្ឋានបច្ចេកទេសសម្រាប់ការសាងសង់សត្តឃាតដ្ឋាន បានតម្រូវឱ្យម្ចាស់សត្តឃាតដ្ឋានដែលបានបង្កើតសត្តឃាតដ្ឋានធ្វើការរៀបចំប្រព័ន្ធបង្ហូរកាកសំណល់ឥតប្រយោជន៍គ្រប់ប្រភេទ ត្រូវតែបញ្ចេញចោលពីកន្លែងធ្វើការជាប្រចាំ ដោយត្រូវស្តុកទុកក្នុងអាងដែលមានគម្របអាចបិទបើកបាន និងប្រមូលចោលជាអចិន្ត្រៃយ៍ ដើម្បីការពារកុំឱ្យមានក្លិន សត្វចង្រៃផ្សេងៗចេញ ចូលបាន ជៀសវាងមានការចម្លងមេរោគដល់សាច់ ផលិតផលសត្វ ទឹកស្អាត និងឧបករណ៍ប្រើប្រាស់ផ្សេងទៀត និងជាប្រយោជន៍ការពារសុខភាពសាធារណៈ និងបរិស្ថាន។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការរៀបចំប្រព័ន្ធបង្ហូរកាកសំណល់ពុំទាន់ត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសឡើយ ដោយម្ចាស់សត្តឃាតដ្ឋានពុំបានរៀបចំប្រព័ន្ធបង្ហូរកាកសំណល់ឥតប្រយោជន៍ស្តុកទុកក្នុងអាងដែលមានគម្របអាចបិទបើកបាន។ បញ្ហានេះ កើតឡើងដោយសារម្ចាស់សត្តឃាតដ្ឋានពុំបានរៀបចំប្រព័ន្ធបង្ហូរកាកសំណល់ឥតប្រយោជន៍គ្រប់ប្រភេទ ដែលត្រូវបញ្ចេញចោល ដោយត្រូវមានគម្របអាចបិទបើកបាន និងកង្វះខាតការយល់ដឹងរបស់ម្ចាស់សត្តឃាតដ្ឋានក្នុងការអនុវត្តភារកិច្ចរបស់ខ្លួនឱ្យសមស្របតាមគោលការណ៍នៃការគ្រប់គ្រងសត្តឃាតដ្ឋាន និងបទដ្ឋានបច្ចេកទេស។

**មតិរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តឧត្តរមានជ័យ**

ក្រោយពីគណៈប្រតិភូសវនកម្ម នៃអាជ្ញាធរសវនកម្មជាតិ បានបញ្ចប់ការងារសវនកម្មលើកិច្ចប្រតិបត្តិការស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាននៅខេត្តឧត្តរមានជ័យសម្រាប់ការិយបរិច្ឆេទ២០២៣ រួមចកឃើញថានៅមានចំណុចខ្វះខាតមួយចំនួនដែលត្រូវធ្វើការកែតម្រូវ និងបំភ្លឺ។ ដូច្នេះមន្ទីរសូមអនុញ្ញាតគោរពឆ្លើយបំភ្លឺ និងសូមឯកភាពស្របតាមការណែនាំរបស់ក្រុមប្រតិភូអាជ្ញាធរសវនកម្មជាតិ ព្រមទាំងបានចាត់ឱ្យការិយាល័យផលិតកម្ម និងបសុព្យាបាល ដឹកនាំមន្ត្រីជំនាញ សហការជាមួយស្ថាប័នពាក់ព័ន្ធរួមមាន រដ្ឋបាលក្រុង និងមន្ទីរបរិស្ថានខេត្ត ចុះធ្វើការណែនាំ និងធ្វើការកែលម្អបន្ថែម។